# ជំងឺសារទឹកគោ-ក្របី



*រៀបរៀងដោយ : នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល*

## ជំងឺសារទឹកជាអ្វី ?

ជំងឺសាទឹកជាជំងឺឆ្លងដ៏សាហាវមួយក្នុងចំណោមជំងឺឆ្លងនានា។ បង្កឡើងដោយបាក់តេរីប៉ាស្ទ័ររ៉ែលឡាម៉ុលតូស៊ីដា (PasteurellaMultocida)។ បាក់តេរីនេះមានរាងជាកូនដំបងខ្លីគ្មានចលនានិងគ្មានស្ព័រ។ ជំងឺសាទឹកកើតលើសត្វគ្រប់ប្រភេទដូចជា សត្វគោ-ក្របី ចៀម ពពែ ជ្រូក។ល។ បណ្តាលឱ្យមានការរលាក និងជាំឈាមនៅតាមសរីរាង្គខាងក្នុង របស់សត្វ ជាពិសេសប្រដាប់ដកដង្ហើម និងប្រដាប់រំលាយអាហារ ជំងឺនេះកើតឡើងរៀងរាល់ឆ្នាំ ហើយច្រើនកើត ឡើងនៅរដូវភ្លៀងធ្លាក់ បណ្តាលឱ្យគោ-ក្របីងាប់យ៉ាង ឆាប់រហ័ស ។

## តើជំងឺសាទឹករាលដាលដោយរបៀបណា ?

ជំងឺសាទឹកគោ-ក្របី ឆ្លងពីសត្វមួយទៅសត្វមួយទៀត តាមរយៈការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ ឬភ្នាក់ងារផ្ទុកជំងឺ ការស៊ីស្មៅ ឬ រុក្ខជាតិនៅកន្លែងដែលមានការផ្ទុះជំងឺ និង មិន ផ្ទាល់ (ពពួកប៉ារ៉ាស៊ីត)។ ចំពោះសត្វក្មេងអាចទទួលជំងឺនេះ យ៉ាងឆាប់រហ័ស។ ជាទូទៅជំងឺនេះអាចរាតត្បាត និងកើតឡើងជាញឹកញាប់នៅពេលអាកាសធាតុប្រែប្រួល ជាពិសេស ក្នុងរដូវភ្លៀងធ្លាក់។

ជាញឹកញាប់គេពិនិត្យឃើញសត្វឆ្លងជំងឺតាមរយៈ

- ការស៊ីចំណី ឬ ផឹកទឹកជាមួយសត្វដែលឈឺ
- សាកសពនៃសត្វដែលងាប់ដោយជំងឺសាទឹកគឺជាប្រភពនៃការចម្លងជំងឺ
- ដីដែលនៅជុំវិញកន្លែងធ្វើការវះកាត់សាកសពនោះក្លាយទៅជា កន្លែងចម្លងមេរោគ ។

## រោគសញ្ញា:

-រយៈពេលមេរោគសំងំមានពី ២-៥ ថ្ងៃ

-សត្វមានអាការៈគ្រុនក្តៅសីតុណ្ហភាពឡើងខ្ពស់កម្លាំងចុះខ្សោយ សត្វចុះស្គមយ៉ាងឆាប់រហ័ស និងមានជាំឈាម នៅតាមស្រទាប់ភ្នាសស្តើងនៃសរីរាង្គខាងក្នុង។ ជាទូទៅយើងពិនិត្យឃើញគោក្របីមានហើមនៅជុំវិញ ក ហើយរាលដាល ដល់ស្មាមុខកន្លែងហើមឡើងក្តៅ មានសភាពទន់ជ្រាយ អណ្តាតអាចហើម និង ធ្លាក់ចេញ



*ការហើមមុខ ក្បាល និង ក ដោយសារការរលាកស្រទាប់ភ្នាសសរីរាង្គខាងក្នុង*

មកក្រៅ ភ្នែកឡើងហើម និងរលាកនៅតាមស្រទាប់ភ្នាសស្តើង ត្របកភ្នែកក្នុង។ សត្វ ហើមពោះ រាគឈាមលាយជាមួយរំអិល សំបោរ រលាកសួត ជីពចរ និងដង្ហើមដើរញាប់ ។

-សត្វអាចងាប់ក្នុងរយៈពេល ៦-២៤ម៉ោង



*ស្លាមជាំឈាមស្រទាប់ភ្នាសសាច់ខាងក្នុងមាត់*



*ស្លាមជាំឈាមស្រទាប់ភ្នាសសាច់ខាងក្នុងនៃ ក*

- ស្លាមជាំឈាមស្រទាប់ភ្នាសសាច់ខាងក្នុងនៃ ក

**វិធានការការពារ:**

- ត្រូវប្រញាប់រាយការណ៍ជូនមន្ត្រីបសុពេទ្យឬភ្នាក់ងារសុខភាពសត្វភូមិដែលនៅជិតអ្នកបំផុតនៅពេលមានឆ្លងជំងឺសាទឹក
- ត្រូវបំបែកសត្វឈឺចេញពីហ្វូង
- ត្រូវធ្វើអនាម័យកន្លែងចិញ្ចឹមជាប្រចាំ
- ជៀសវាងការផ្តល់ចំណី ឬរុក្ខជាតិមានប្រភពពីកន្លែងផ្ទុះ ឬឆ្លងជំងឺ
- ហាមចលនាសត្វចេញ-ចូល ឬ ឆ្លងកាត់តំបន់ផ្ទុះជំងឺ
- ហាមប៉ះពាល់សត្វងាប់ និងពិឃាតសត្វឈឺ ឬសត្វដែលសង្ស័យថាឈឺយកសាច់លក់ ឬបរិភោគ

**វិធានការដែលមានប្រសិទ្ធិភាពបំផុត** ក្នុងការការពារ កុំ ឱ្យគោក្របីកើតជំងឺសាទឹកគឺចាក់វ៉ាក់សាំងការពារ។ ការចាក់វ៉ាក់សាំងដល់សត្វជាមុនអាចការពារមិនឱ្យសត្វឆ្លងជំងឺទោះបីជាវាស្ថិតនៅក្នុងហ្វូងសត្វឈឺក៏ដោយ ។

ការចាក់វ៉ាក់សាំងត្រូវធ្វើឱ្យបានទៀងទាត់តាមប្រតិទិនចាក់ថ្នាំការពារ ។វ៉ាក់សាំងការពារជំងឺសាទឹកផ្តល់ភាពស៊ាំ បានរយៈពេល ៦ ខែ ចំពោះថ្នាំប្រភេទរាវ និង ១២ ខែចំពោះថ្នាំ ប្រភេទខាប់ ។ ថ្នាំការពារសត្វសម្រាប់ប្រឆាំងនឹងជំងឺសាទឹកគោ-ក្របី





*ថ្នាំការពារសត្វសម្រាប់ប្រឆាំងនឹងជំងឺសាទឹកគោ-ក្របី*

**ការការពារប្រសើរជាងការព្យាបាល**